រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ
# មហាសន្និបាតភាគហ៊ុនិកលើកទី៥

**ក/.កាលបរិច្ឆេទ** ៖ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ ចាប់ពីម៉ោង៨:០០ព្រឹក

**ខ/.ទីកន្លែង** ៖ សាលប្រជុំរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

**គ/.សមាសភាពចូលរួម៖**

- គណៈអធិបតី ៖
  - ១. ឯកឧត្តម សឺម ណារ៉ា — ប្រធានក្រុមប្រឹក្សាភិបាល
  - ២. ឯកឧត្តម ស៊ឹម ស៊ីថា — អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
  - ៣. លោក ឡុង ណារ៉ូ — សមាជិកក្រុមប្រឹក្សាភិបាល - តំណាងនិយោជិត
  - ៤. លោកឧកញ៉ា ចាង យុនហ្វេង — សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន
  - ៥. លោក អោម សេងបូ៉ា — សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលឯករាជ្យ
- ភ្ញៀវកិត្តិយស ៖
  - ១. ឯកឧត្តម នេត មុន្នី — មន្ត្រីត្រួតពិនិត្យរដ្ឋ អម រ.ទ.ស.ភ
  - ២. លោក ចិន សេងហ៊ាង — តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម
  - ៣. លោក ជូ វណ្ណៈ — តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - ៤. លោកស្រី សេង គាតារា — ប្រធានសវនកម្មផ្ទៃក្នុង នៃ រ.ទ.ស.ភ
  - ៥. លោក Ronald Coronel Almera — តំណាងក្រុមហ៊ុនសវនកម្មឯករាជ្យ ហ្គ្រេន សនថុន
  - ៦. ឯកឧត្តម សៀង ធីរិទ្ធ — តំណាងគណៈកម្មការមូលបត្រកម្ពុជា
  - ៧. លោកស្រី យូ កញ្ញារី — តំណាងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
  - ៨. លោក ស៊ីយ៉ា ម៉ាលីដា — តំណាងធនាគារអេស៊ីលីដា ភីអិលស៊ី
  - ៩. ឯកឧត្តម ណែម ធីម — តំណាងកំពង់ផែស្វយ័តភ្នំពេញ

  ព្រមទាំងភ្ញៀវកិត្តិយសជាច្រើនរូបទៀត ដែលជាតំណាងមកពីបណ្តាក្រុមហ៊ុនមូលបត្រនានា។
- លេខាកត់ត្រា ៖
  - ១. លោកបណ្ឌិត ជា វិសុទ្ធ — អគ្គនាយករងទទួលបន្ទុកជាលេខាសហគ្រាស
  - ២. លោក ហួត សុខហេង — នាយលេខាធិការដ្ឋាន។
- អ្នកចូលរួម ៖ ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះនៅភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ រ.ទ.ស.ភ (ធនាគារអេស៊ីលីដា ភីអិលស៊ី) ដើម្បីត្រៀមចូលរួមមហាសន្និបាតមានចំនួន១០៥នាក់ គិតជាភាគហ៊ុនមានចំនួន៧៥.៩៩៨.៥២២ហ៊ុន ស្មើនឹង៨៧,៣៨%នៃភាគហ៊ុនធម្មតាសរុប។ ភាគហ៊ុនិកដែលបានចុះវត្តមាននិងបានចូលរួមមហាសន្និបាតជាក់ស្តែងមានចំនួន៨៧នាក់ គិតជាភាគហ៊ុនមានចំនួន៧៥.៩០៥.៨៥៨ហ៊ុន (ស្មើនឹង៨២,៨៦%នៃចំនួនភាគហ៊ុនដែលបានចុះឈ្មោះចូលរួម) ក្នុងនោះលោក ជូ វណ្ណៈ អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាអាណត្តិគាហកៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ឃ/.ដំណើរការនៃមហាសន្និបាត**

**១/.បទបង្ហាញស្តីពីលទ្ធផលអាជីវកម្មឆ្នាំ២០១៦ និងទិសដៅអាជីវកម្មឆ្នាំ២០១៧**

ដោយមានការអនុញ្ញាតពីឯកឧត្តមប្រធានគណៈអធិបតី លោក រស់ គឹមលាង អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ចនិងផ្សារមូលបត្រ បានធ្វើរបាយការណ៍ជូនអង្គមហាសន្និបាតជ្រាបពីលទ្ធផលអាជីវកម្មឆ្នាំ២០១៦ និងទិសដៅអាជីវកម្មឆ្នាំ២០១៧ តាមរយៈការបញ្ចាំងស្លាយជាភាសាខ្មែរនិងភាសាអង់គ្លេស ដោយមានគោលខ្លឹមសារសំខាន់ៗ ដូចមានក្នុងឯកសារសម្រាប់មហាសន្និបាត។ លោកក៏បានធ្វើការកត់សម្គាល់ផងដែរថា ៖

ក) ជារួម **ក្នុងឆ្នាំ២០១៦** រ.ទ.ស.ភ ផលិតទឹកស្អាតសរុប១៧៨.២៣៤.០៣៩ម៣, ដាក់បំពង់ចែកចាយបានប្រវែង១៩៥គ.ម និងបានរក្សាអត្រាទឹកបាត់បង់ក្នុងរង្វង់៧%។ ទន្ទឹមគ្នានោះ តបណ្តាញជូនអតិថិជនបានចំនួន២១.៨១១បណ្តាញ ក្នុងនោះអតិថិជនចំណូលទាបមានចំនួន១.២៤០បណ្តាញ។ អត្រាប្រមូលប្រាក់ថ្លៃទឹកអនុវត្តបាន៩៩,៩០%។ ក្រៅពីនេះ ចំណូលសរុបប្រចាំឆ្នាំ គឺប្រមាណ១៩៨ពាន់លានរៀល ដែលជាហេតុធ្វើឱ្យទទួលប្រាក់ចំណេញពិតចំនួន៥៩៣ពាន់លានរៀល។ ទ្រព្យសកម្មកើនឡើងដល់ ១.២៩៧ពាន់លានរៀល។

ខ) បណ្តាសន្ទស្សន៍សំខាន់ៗដែលសម្រេចបានក្នុង**ឆ្នាំ២០១៦** គឺ ៖

| | | |
|---|---|---|
| ១. | អនុបាតចរន្ត | ៣,៩៥ ដង |
| ២. | អត្រាអនុបាតចរន្តលឿន | ៣,២៤ ដង |
| ៣. | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ៣,៨៧% |
| ៤. | ផលចំណេញក្នុងមួយឯកតាមូលធន | ៦,១៤% |
| ៥. | ចំណេញក្នុងមួយឯកតាកម្មសិទ្ធិ | ៥៦៦,៥៣ រៀល |
| ៦. | ភាគលាភក្នុងមួយឯកតាកម្មសិទ្ធិ | ១៥៩,៩៩ រៀល |

សូមបញ្ជាក់ថា អត្រាបែងចែកភាគលាភ (Dividend Payout Ratio) បានកើនឡើងពី៧% ក្នុងឆ្នាំ២០១២ ដល់២៨,២៤% ក្នុងឆ្នាំ២០១៦នេះ។

គ) ទិសដៅសំខាន់ៗនៃអាជីវកម្មក្នុង**ឆ្នាំ២០១៧** គឺ ៖

| | | |
|---|---|---|
| ១. | បរិមាណទឹកផលិត | ២០៤.៥៧៦.២៨០ ម៣ |
| ២. | តបណ្តាញចូលផ្ទះថ្មី | ២២.០០០ បណ្តាញ |
| ៣. | ចំនួនអតិថិជនចុងគ្រានាដំណាច់ឆ្នាំ | ៣៣០.៣៣០ បណ្តាញ |
| ៤. | បរិមាណទឹកលក់ | ១៨៨.២១០.៥៤០ ម៣ |
| ៥. | អត្រាធ្វើវិក្កយបត្រ | ៩២,00% |
| ៦. | អត្រាទារប្រាក់ | ៩៩,៩០% |
| ៧. | ថ្លៃទឹកលក់ជាមធ្យម/ម៣ | ១.០៣២ រៀល |
| ៨. | ចំណូលសរុប | ២៣៣.៣២០.១៧៣.០០០ រៀល |
| ៩. | ចំណាយសរុប | ១៧២.៣៥០.៨១១.០០០ រៀល |
| ១០. | ចំណេញពិត | ៤៨.៧៧៥.៤៩០.០០០ រៀល។ |

ឃ) រ.ទ.ស.ភ គ្រោងនឹងបង្កើនប្រសិទ្ធភាពដំណើរការអាជីវកម្ម និងពង្រីកសមត្ថភាពផលិតបន្ថែម តាមរយៈគម្រោងសំខាន់ៗចំនួន៤គឺ៖

(១) បន្តអនុវត្តគម្រោងប្រព័ន្ធចេញវិក្កយបត្រទឹកជូនដល់អតិថិជនផ្ទាល់នឹងកន្លែង (Spot Billing) នៅបណ្តាខណ្ឌផ្សេងៗទៀតក្នុងរាជធានីភ្នំពេញ និងឈានទៅអនុវត្តនៅទូទាំងផ្ទៃសេវារបស់ រ.ទ.ស.ភ ក្រោយពីអនុវត្តសាកល្បងបានជោគជ័យនៅក្នុងខណ្ឌចំការមន។

(២) គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតចំការមន សមត្ថភាពផលិត៥២.០០០ម$^{៣}$/ថ្ងៃ ដោយប្រើប្រាស់ហិរញ្ញប្បទានផ្ទាល់ពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)

(៣) គម្រោងទិញពីក្រុមហ៊ុន អានកូ នូវអាជ្ញាប័ណ្ណផ្គត់ផ្គង់ទឹកស្អាតនៅសង្កាត់ចំនួន៤ ក្នុងខណ្ឌច្បារអំពៅ។

(៤) គម្រោងកាត់បន្ថយឧស្ម័នកាបូនិក ($CO_2$) ដើម្បីបន្ថយចំណាយលើថាមពល និងចូលរួមកាត់បន្ថយកម្តៅផ្ទះកញ្ចក់។

## ២/. សំណួរ-ចម្លើយ

(គ្មាន)

## ៣/. មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ

ឯកឧត្តមប្រធានគណៈអធិបតី បានជម្រាបដោយសង្ខេបជូនមហាសន្និបាត អំពីលទ្ធផលអាជីវកម្មឆ្នាំ២០១៦ និងផែនការឆ្នាំ២០១៧ ដោយសង្ឃឹមជឿជាក់ថា ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងភាគហ៊ុនិកទាំងអស់ដែលបានអញ្ជើញចូលរួម ពិតជាពេញចិត្តចំពោះលទ្ធផលដែល រ.ទ.ស.ភ សម្រេចបាន និងភាគលាភដែលបានបែងចែកជូនភាគហ៊ុនិករួចហើយនោះ។

លើសពីនេះ ឯកឧត្តមបានលើកឡើងថា នៅក្នុងឆ្នាំ២០១៧ និងបណ្តាឆ្នាំខាងមុខ ដើម្បីឈានទៅសម្រេចទស្សនវិស័យរបស់ រ.ទ.ស.ភ ដែលបានកំណត់ថា *"ធ្វើឲ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងជាអ្នកផ្តល់ប្រឹក្សា និងជាអ្នកសម្របសម្រួល ដើម្បីប្រជាពលរដ្ឋនៅតាមទីប្រជុំជនខេត្ត-ក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅបណ្តាប្រទេសកំពុងអភិវឌ្ឍ មានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា"* យើងត្រូវបន្តយកចិត្តទុកដាក់ទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

- បំពេញផ្ទៃសេវានៅរាជធានីភ្នំពេញ ឲ្យបាន១០០% នៅត្រឹមឆ្នាំ២០២៥។
- ខិតខំធ្វើយ៉ាងណាឲ្យអត្រាដំណើរការសហគ្រាស មិនលើសពី៤០%។
- ធានានូវអត្រាទារប្រាក់ប្រើប្រាស់ទឹក មិនឲ្យទាបជាង៩៩%។
- រក្សាអត្រាទឹកបាត់បង់ ឲ្យស្ថិតនៅក្រោម១០% ក្នុងរង្វង់៧%។
- ចូលរួមអនុវត្តជាបន្ទាន់ នូវគោលនយោបាយថ្លៃទឹកថ្មីរបស់រាជរដ្ឋាភិបាល ដែលបានប្រកាសនាពេលថ្មីៗនេះគឺ បរិមាណទឹកប្រើប្រាស់ប្រចាំខែពី ០ម$^{៣}$ ទៅ ៣ម$^{៣}$ លក់ក្នុងតម្លៃ៤០០រៀល/ម$^{៣}$ និងពី ៤ម$^{៣}$ ទៅ ៧ម$^{៣}$ តម្លៃ៥០០រៀល/ម$^{៣}$ ដែលបច្ចុប្បន្ន លក់ក្នុងតម្លៃ៥៥០រៀល/ម$^{៣}$។

ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមបានថ្លែងនូវការកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រី-និយោជិត រ.ទ.ស.ភ ទាំងអស់ ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវ និងនាំមកនូវការរីកចម្រើន និងជោគជ័យដ៏ត្រចះត្រចង់នេះ។ ជាមួយនឹងការទទួលបាននូវពានរង្វាន់អន្តរជាតិជាបន្តបន្ទាប់ ទៅលើគុណភាព និងការដឹកនាំគ្រប់គ្រងអង្គភាព រ.ទ.ស.ភ តែងទទួលបានការកោតសរសើរពីសំណាក់ក្រសួងអាណាព្យាបាលទាំងពីរ (ក្រសួងឧស្សាហកម្មនិងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ចំពោះការផ្គត់ផ្គង់ទឹកប្រកបដោយសមត្ថភាព, គុណភាព, និរន្តរភាព និងតម្លៃសមរម្យសម្រាប់ប្រជាពលរដ្ឋ។

ទន្ទឹមគ្នានោះ ក៏បានសម្តែងនូវការដឹងគុណចំពោះក្រសួងអាណាព្យាបាលទាំងពីរ, សាលារាជធានីភ្នំពេញ, គណៈកម្មការមូលបត្រកម្ពុជា, ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលតែងបានផ្តល់ទំនុកចិត្ត និងគាំទ្រដល់ រ.ទ.ស.ភ ។

ជាកិច្ចបញ្ចប់នៃមហាសន្និបាត ឯកឧត្តមប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត បានថ្លែងអំណរគុណចំពោះ គណៈអធិបតី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងសមាជិកនៃអង្គសន្និបាតទាំងមូល ដែលបានអញ្ជើញចូលរួម និងបាន ខិតខំបំពេញភារកិច្ចរបស់ខ្លួន ធ្វើឱ្យមហាសន្និបាតភាគហ៊ុនិកលើកទី៥របស់ រ.ទ.ស.ភ ប្រព្រឹត្តទៅដោយជោគជ័យ។

មហាសន្និបាតបានបញ្ចប់នាម៉ោង១០:១៥នាទីព្រឹក នៃថ្ងៃនិងខែឆ្នាំដដែល។

**លេខាធិការសហគ្រាស**

**ប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត**
**ប្រធានក្រុមប្រឹក្សាភិបាល**

**បណ្ឌិត ជា វិសុទ្ធ**

**ស៊ឹម_ណារ៉ា**

<u>**កន្លែងទទួល**</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឯកឧត្តមប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- មន្ត្រីត្រួតពិនិត្យរដ្ឋអមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- គណៈកម្មការមូលបត្រកម្ពុជា

  *" ដើម្បីជូនជ្រាប"*
- គ្រប់អង្គភាពចំណុះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

  *" ដើម្បីមុខការ"*
- ឯកសារនិងកាលប្បវត្តិ។